# ពិធីសំពះគ្រូរបាំក្បាច់បុរាណខ្មែរ

នៅថ្ងៃទី១៤កើត ខែស្រាព ព.ស. ២០៦៦ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១១ ខែសីហា ឆ្នាំ ២០២២ នាទីស្តីការសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ «ពិធីបួងសួងរំឭកវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធព្រះបរមគ្រូ» បានត្រូវរៀបចំនិងប្រារព្ធធ្វើឡើងដោយសិល្បករនិងសិល្បការិនីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី និងលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

នៅក្នុងឱកាសដ៏សក្ការៈនេះ គ្រូស្រីនិងអ្នកចំរៀងពាក់អាវប៉ាក់ពណ៌ស និងក្បិនពណ៌បៃតង ទៅតាមថ្ងៃប្រពៃណីពណ៌ថ្ងៃព្រហស្បតិ៍។

នៅផ្នែកម្ខាងនៃវេទិកាបុណ្យ មានព្រះសង្ឃ ៩អង្គ និងបារគូ បីនាក់ ហើយនៅម្ខាងទៀត មានម្កុដនិងមុខខ្នុកព្រមទាំងជផ្កាយមានម្ហូបចំណី បង្អែម ផ្លែឈើ លាជ និងទឹកអប់ប្រេងម្សៅ ទៀនធូប ព្រមទាំងប្រទីបផ្កាលា រៀបចំជារណ្តាប់ថ្វាយ។ ឯអ្នកចូលរួមក្នុងពិធីអង្គុយបត់ជើងនៅកណ្តាលវេទិកាបុណ្យ។

ជាប្រពៃណី គេជ្រើសរើសយកថ្ងៃព្រហស្បតិ៍ដើម្បីប្រារព្ធពិធីនេះ ព្រោះថ្ងៃព្រហស្បតិ៍ជាថ្ងៃដែលមានថាមពលខ្លាំងជាងថ្ងៃឯទៀតៗនិងជា «ថ្ងៃគ្រូ» ផង។ នៅពេលមុននឹងពិធីចាប់ផ្តើម សិស្សរៀងៗខ្លួន ជូនទៀននិងធូបទៅគ្រូដែលបានបង្រៀនខ្លួន។

ពិធីសំពះគ្រូ ចែកជាបីដំណាក់៖ (១) ពិធីបួងសួងរំឭកគ្រូ (វប្បធម៌ ភ្លេង របាំ) (២) ពិធីសាសនា និង (៣) ពិធីបួងសួងរំឭកគ្រូ (វប្បធម៌ ភ្លេង របាំ)។

(១) ពិធីបួងសួងរំឭកគ្រូ (វប្បធម៌ ភ្លេង របាំ)

អ្នកចូលរួមទាំងអស់បែរមុខទៅរកអសនៈ ទីសក្ការៈតម្កល់ជផ្កាយ ម្កុដ និងមុខខ្នុក។

១. អាចារ្យ ចាប់ផ្តើម (មើលគ្រាំង) ឧទ្ទិសបួងសួង ប្រកាសសូមពរជ័យ សូត្ររំឭកឈ្មោះគ្រូទាំងអស់ដែលបានចែកឋានទៅ។ អាចារ្យ យាងនិងអញ្ជើញគ្រូ គ្រូស្រែក គ្រូច្រៀង គ្រូហោសូមឱ្យមកចូលរួមក្នុងពិធី។ អាចារ្យថ្វាយភ្លេង ដោយហៅឈ្មោះភ្លេង និងបទភ្លេងពិណពាទ្យ៖

១. សាធុការ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

២. ប្រោសព្រំគ្រូធំ

៣. ផ្ចិ

៤. ហក់

៥. ដំណើរសត្វខ្ទុម

៦. ពាទ័សាម៉ាឡា (ពាទ័ ៣ជាន់)

៧. ស្មើខណ្ឌសមុទ្រ

៨. ដើតធាន

៩. សន្ទឹកក្នុង ៣ជាន់

១០. ខែកបរិច្ឆេទ (ខែកបរិឆេត)

១១. បឋម (ប្រធំ)

១២. ពោលខោលដោយអាចារ្យ - ទទួលដោយសិស្ស (ភ្លេងបទដើតចាប់)

១៣. សិស្សរាំថ្វាយដង្វាយ រាំបែរមុខទៅទិសទាំងបួន។

(២) ពិធីសាសនា

អ្នកចូលរួមទាំងអស់ បែរមុខទៅព្រះពុទ្ធរូបនិងព្រះសង្ឃ។

១៤. សាធុការ (គណៈធិបតីនិងគ្រូ អុជទៀនធូប បាញ់ទឹកអប់ទៅលើព្រះភ័ក្ត្រព្រះឈយាលក្ខណ៍)។ បារគូបីនាក់ សូត្រនៅមុខអសនៈនិងព្រះឈយាលក្ខណ៍ បួងសួងសូមពរជ័យ អញ្ជើញព្រលឹងគ្រូសូមឱ្យមកចូលរួមនិងដឹងឮ។ រួចហើយ បារគូផ្លុំស័ង្ខ បីដង។

១៥. សាធុការ

១៦. ព្រះសង្ឃ ៩អង្គ នមសិការ សូមព្រះវិញ្ញាណក្ខន្ធនៃគ្រូដែលបានចែកឋានទៅ សូមភ្ញាក់ស្មារតី។ ពុទ្ធសាសនិកចូលរួមក្នុងពិធី សូត្រ នមោទស្ស។ ព្រះសង្ឃ សូត្ររំឭកគ្រូ បែបបុរាណដែលមានភាពខុសប្លែកពីធម្មតាដែលធ្លាប់ឮ។ បន្ទាប់ពីព្រះសង្ឃនមសិការ អាចារ្យនាំសូត្របន្ត («អនុមោទនា»)។ ជាបន្ទាប់ គឺការវេរថ្វាយ ដោយអាចារ្យសូត្របន្ត (ស្ងឹងស្ងាធ ប្រមូលអារម្មណ៍ រួចថាតាមអាចារ្យ)។ អាចារ្យហៅឈ្មោះគ្រូ ប្រកាសថា «បានចាត់ចែងនាំមកហើយនូវចង្ហាន់បិណ្ឌបាត បានមកដោយធម៌ កើតឡើងដោយធម៌ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គជាប្រធាន»។ ពិធីបង្សុកូលជាបន្ត អ្នកចូលរួមទាំងអស់ បែរមុខទៅព្រះ

ធយាលក្ខណ៍ សូត្រធម៌ ស្រោចទឹកថ្វាយនិងជូន ប្រោសព្រំដោយគ្រូ ហើយមានភ្លេងទទួលបន្ទិច រួចចប់ពិធីសាសនា (ព្រះសង្ឃនិមន្តនិវត្តត្រឡប់ទៅវិញ)។

(៣) ពិធីបួងសួងរំឭកគ្រូ (វប្បធម៌ ភ្លេង របាំ)

អ្នកចូលរួមទាំងអស់បែរមុខទៅរកអសនៈ ទីសក្ការៈតម្កល់ជង្ហាយ ម្កុដ និងមុខខ្នក។ នៅក្នុងពិធីស្រង់ទឹក អាចារ្យហៅភ្លេងបន្ត។

១៧. ភ្លេងស្រង់ទឹក (គ្រូបាញ់ទឹកអប់លើម្កុដនិងមុខខ្នក)

១៨. ភ្លេងសែនព្រេន

១៩. ភ្លេងបាចលាជ (បាចលាជលើម្កុដនិងមុខខ្នក)

២០. សិស្សរាំថ្វាយ ទៅតាមតួ៖ យក្ស ស្វា នាង និងនាយរោង (ភ្លេងខែកមន ២ជាន់ ៣បញ្ចុះ)

២១. បទព្រះថោង (មានចម្រៀង) រាំរបាំព្រះថោង

២២. របាំបួងសួងព្រាហ្មណ៍

២៣. របាំបាចផ្កា

២៤. របាំអប្សរា (ដោយសិស្សមកពីប្រទេសបារាំង (*Ballet Classique Khmer*))

២៥. បង្វិលពពិល

២៦. ដើតជូនគ្រូ

(ចប់ពិធី)

ពិធីទាំងមូល មានរយៈពេលប្រមាណ ២ម៉ោងកន្លះ (ពីម៉ោង ៨:០០ ដល់ម៉ោង ១០:៣០)។ បន្ទាប់ពីពិធីសំពះគ្រូបានប្រារព្ធធ្វើសព្វគ្រប់ហើយ អ្នកចូលរួមនិងពុទ្ធសាសនិកក៏បានចូលរួមនៅក្នុងពិធីរាប់បាតជាបន្តរហូតដល់ចប់។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង